# Living the Lotus

*Buddhism in Everyday Life*

8
2026
VOL. 251



## Dharma Centers Across India Observe Ancestor Veneration Weeks, July 1–15: Members Perform the Ullambana Ceremony on July 15 with Hearts Full of Gratitude

**Living the Lotus**
**Vol. 251 (August 2026)**

【発行】 立正佼成会 国際伝道部
〒166-8537
東京都杉並区和田2-7-1 普門メディアセンター3F
Tel: 03-5341-1124　Fax: 03-5341-1224
E-mail: iiving.the.lotus.rk-international@kosei-kai.or.jp
編集責任者: 前田 貴史
編集チーフ: 三川 紗知
校閲者: 小坂 和正、菊池 克之
編集スタッフ： 国際伝道部スタッフ

立正佼成会は1938年に庭野日敬開祖、長沼妙佼脇祖によって創立された、法華三部経を所依の経典とする在家仏教教団です。家庭や職場、地域社会の中で釈尊の教えを生かし、平和な世界を築いていきたいと願う人々の集まりです。現在は庭野日鑛会長とともに、私たち会員は仏教徒として布教伝道に励みながら、宗教界をはじめ各界の人々と手をたずさえ、国内外でさまざまな平和活動に取り組んでいます。

Living the Lotus—Buddhism in Everyday Life（法華経を生きる～生活の中の仏教）というタイトルには、日々の生活のなかに法華経の教えを活かして、泥水に咲く美しい蓮の花のように、人生を豊かに、そしてより価値あるものにしていきたいとの願いが込められています。本誌を通じて、世界中の人々に日々の生活のなかで活かす仏教の教えをお伝えします。

# «ប្រសិនបើអ្នកដុតចន្លុះបំភ្លឺផ្លូវឱ្យគេ» ឬប្រសិនបើអ្នកធ្វើអ្វីជាប្រយោជន៍ដល់អ្នកដទៃ

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្សូកូសេកៃ



## «ធ្វើអ្វីជាប្រយោជន៍ដល់អ្នកដទៃ»តើធ្វើជាប្រយោជន៍ដល់អ្នកណា?

ជារឿយៗយើងនិយាយអំពីការរស់នៅដោយពឹងពាក់គ្នាទៅវិញទៅមកដែលជាគុណតម្លៃនៃនិស្ស័យឬទំនាក់ទំនងជាមួយមនុស្សនិងមនុស្ស។ជនជាតិជប៉ុនទទួលយកពាក្យថា"ជួយគ្នាក្នុងគ្រាក្រ" "ធ្វើដំណើរត្រេចចរត្រូវមានគ្នីគ្នាជួយគិត នៅលើផ្លូវជីវិតត្រូវមានក្តីមេត្តា"មកធ្វើជាវិថីបេះដូងរបស់ខ្លួនយ៉ាងធម្មតាជាយូរមកហើយ ។

អំបាញមិញខ្ញុំព្រះករុណាអាត្មាភាពបាននិយាយពី"ជនជាតិជប៉ុន"ប៉ុន្តែនៅសាធារណរដ្ឋហ្កាណាក្នុងទ្វីបអាហ្វ្រិក ឧទាហរណ៍ មានជំនឿមួយបានចាក់ឫសយ៉ាងជ្រៅទៅក្នុងចិត្តរបស់មនុស្សជាច្រើន៖"មិនថាមនុស្សទុរគតយ៉ាងណាទេគេនឹងមិនស្លាប់កណ្តោចកណ្តែងចោលឆ្អឹងកណ្តាលវាលដូចសត្វធាតុនោះឡើយ"។

ប្រាកដជាមាននរណាម្នាក់បោះដៃទៅជួយឬជ្រោមជ្រែងគេ។ ដោយសារតែគេមានជំនឿជឿជាក់បែបនេះអ្នកស្រុកហ្កាណាមិនមើលបំណាំគ្នាហើយជួយគ្នាទៅវិញទៅមក។ ដូច្នេះជនជាតិហ្កាណាណាម្នាក់ក៏រស់នៅប្រកបដោយសេចក្តីរីករាយមានទឹកមុខញញឹមញញែមគ្មានក្តីព្រួយបារម្ភ។ខ្ញុំព្រះករុណាឮគេហៅបាតុភូតនេះថា«វេទមន្តហ្កាណា»។

វប្បធម៌ដែលផ្អែកទៅលើតម្លៃសម្បទានិងទំនៀមទម្លាប់ជួយគ្នាទៅវិញទៅមករួមជាមួយនឹងឈ្មោះដែលគេហៅបាតុភូតតាមស្រុកនីមួយៗនោះប្រាកដជាមាននៅទូទាំងពិភពលោក។

ក្នុងន័យដូចគ្នានេះក៏មានសុភាសិតជប៉ុនមួយចែងថា"សេចក្តីមេត្តាមិនមែនសម្រាប់តែផ្តល់ដល់អ្នកដទៃទេ"។ គឺជាសុភាសិតដែលជនជាតិជប៉ុនណាម្នាក់ក៏ស្គាល់ដែរ។ មិនបាច់និយាយក៏អ្នកដឹងដែរថាសុភាសិតនេះមានន័យថាសេចក្តីមេត្តាឬសមានចិត្តដែលយើងបង្ហាញដល់អ្នកដទៃនៅទីបំផុតនឹងត្រឡប់មករកយើងវិញផ្តល់ប្រយោជន៍ដល់ខ្លួនយើងដែលជាសក្ខីភាពបង្ហាញថាពិភពលោកគឺជាកន្លែងនៃការផ្តល់ដល់គ្នានិងការទទួលយកពីគ្នាទៅវិញទៅមក។

ម្យ៉ាងទៀតព្រះសង្ឃដីការបស់ព្រះគ្រូនិជីរ៉េង (Saint Nichiren) បង្ហាញយ៉ាងច្បាស់ពីសារៈសំខាន់និងកុសលផលបុណ្យដែលបានពី*ការធ្វើផ្តល់ឬការធ្វើទាន*— ប្រសិនបើអ្នកផ្តល់អ្វីមួយដល់អ្នកដទៃអ្វីនោះវាក្លាយជាអ្វី

ដែលជួយអ្នកដូចជាការដុតចន្លុះបំភ្លឺផ្លូវឲ្យអ្នកដទៃវាបំភ្លឺផ្លូវដែលនៅពីមុខអ្នកដូច្នេះដែរ —ការបង្រៀននេះវាស្របនឹងសុភាសិតថា"សេចក្តីមេត្តាមិនមែនសម្រាប់តែផ្តល់ដល់អ្នកដទៃទេ"។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ខ្ញុំព្រះករុណាអាត្មាភាពបានឮថាសព្វថ្ងៃនេះមានមនុស្សមួយចំនួនមានចម្ងល់ឬមានអារម្មណ៍មិនស្រួលចិត្តចំពោះមនោសញ្ចេត នានិងទង្វើ"ជាប្រយោជន៍ដល់អ្នកដទៃ"។

មនុស្សមិនតិចទេយល់ថាទង្វើ"ដើម្បីប្រយោជន៍អ្នកដទៃ" គឺជាការលះបង់ខ្លួនឯង។ ពួកគេមិនសប្បាយចិត្តក្នុងការចាត់ទុកទង្វើនេះថាជាគុណធម៌ហើយគេមិនចង់លះបង់ពេលវេលារបស់គេដើម្បីប្រយោជន៍អ្នកដទៃទេ។

នៅក្នុងស្ថានភាពដូចសព្វថ្ងៃបែបនេះតើយើងអាចរក្សាសង្គមដ៏សប្បុរសមួយដែលមនុស្សណាក៏អាចរស់នៅបានប្រកបដោយសុខមាលភាពគ្រប់គ្នា—ជាសង្គមដែលស្មារតីនៃការជួយគ្នាទៅវិញទៅមកនិងពឹងពាក់លើគ្នាទៅវិញទៅមកឬគំនិតម្តងគេម្តងយើងត្រូវបានអនុវត្តយ៉ាងធម្មតាដោយគ្មានការស្ទាក់ស្ទើរនៅគ្រប់ទីកន្លែងឬទេ?

## នមោ ព្រះពោធិសត្វស្ម័គ្រចិត្ត

ខ្ញុំព្រះករុណាអាត្មាភាពគិតថានឹងមានអ្នកដែលប្រើប្រាស់វិស្សមកាលរដូវក្តៅនេះដើម្បីលះបង់ពេលវេលារបស់ពួកគេសម្រាប់អ្នកដទៃដោយចូលរួមក្នុងសកម្មភាពស្ម័គ្រចិត្ត។

ពាក្យថា"អ្នកស្ម័គ្រចិត្ត" សំដៅទៅលើអ្នកដែលធ្វើការផ្តល់សេវាដល់អ្នកដែលខ្វះខាតឬមានការលំបាកដោយសារតែក្តីមេត្តាដោយចិត្តឯងគ្មាននរណាបង្ខិតបង្ខំ។ គំនិតនៃ *សកម្មភាពស្ម័គ្រចិត្ត* ក៏បង្កប់ន័យនៃការបម្រើទេព ដូចជាព្រះ ឬព្រះពុទ្ធជាដើមដែរ។ នៅពេលទៅធ្វើទស្សនកិច្ចនៅតំបន់ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយរួមទាំងការរញ្ជួយដីដ៏ធំអស្វារ្យហាំងស៊ីនអាវ៉ាជី (Hanshin-Awaji )(ដែលបានប្រារព្ធខួបលើកទី 30 របស់ខ្លួនកាលពីឆ្នាំមុន) ការរញ្ជួយដីដ៏ធំនៅប្រទេសជប៉ុនភាគខាងកើតនិងការរញ្ជួយដីនៅគីម៉ាម៉ូតូ( Kumamoto) ខ្ញុំព្រះករុណាអាត្មាភាពបានឃើញអ្នកស្ម័គ្រចិត្តធ្វើការដោយមិនខ្លាចនឿយហត់ដើម្បីជួយសម្រាលទុក្ខលំបាករបស់ជនរងគ្រោះ។ អាកប្បកិរិយារបស់ពួកគេដែលមើលទៅឃើញដូចជាគេកំពុងតែបម្រើទេពឬលះបង់ខ្លួនឯងដើម្បីជីវិតដ៏មានតម្លៃនីមួយៗនោះ បានធ្វើឱ្យខ្ញុំព្រះករុណាអាត្មាភាពរំជួលចិត្តយ៉ាងខ្លាំង។ខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ថាអ្នកទាំងនេះគឺជា*ព្រះពោធិសត្វ *ពិតៗ។ ជំនួបនឹង"ព្រះពោធិសត្វស្ម័គ្រចិត្ត" ទាំងនេះ បង្រៀនខ្ញុំព្រះករុណាអាត្មាភាពថាមនុស្សយើងមានសេចក្តីប្រាថ្នាពីកំណើត មិនមែនដើម្បីតែសេចក្តីសុខផ្ទាល់ខ្លួនទេ ប៉ុន្តែស្វែងរកសេចក្តីសុខរួមគ្នាជាមួយនឹងអ្នកដទៃ។

ម៉្យាងវិញទៀតសម្រាប់អ្នកដែលមិនអាចទទួលយកគំនិតធ្វើអ្វីមួយជាប្រយោជន៍ដល់អ្នកដទៃ ទោះបីជាយើងនិយាយប្រាប់ពួកគេថា"ក្នុងលោកនេះយើងរស់នៅបានដោយការជួយគ្នាទៅវិញទៅមក"ក៏ប្រហែលជាគ្មានប្រសិទ្ធភាពដែរ។ ពីព្រោះថាមនុស្សម្នាក់ៗគ្រប់រូបមានវិធីគិតរៀងៗខ្លួន ការបង្ខំគេឱ្យទទួលយកតម្លៃសម្បទាឬគំនិតរបស់យើងវាជំរុញឱ្យមនុស្សឃ្លាតឆ្ងាយទៅវិញទេ។

ទោះជាយ៉ាងណាក៏ដោយគំនិតថា"បេះដូងកាន់កាប់ពិភពដប់ពីនរកដល់មេឃ"បង្រៀនយើងថាមនុស្សគ្រប់រូបមានបេះដូងរបស់ព្រះពុទ្ធ ឬព្រះពោធិសត្វហើយមានចេតនាចង់ធ្វើឱ្យពិភពលោកឡើងកាន់តែល្អប្រសើរ។ ប្រសិនបើយើងជឿជាក់លើគំនិតនេះ ហើយលះបង់ខ្លួនយើងទាំងផ្លូវកាយនិងចិត្ត—ដើម្បីធ្វើប្រយោជន៍ដល់អ្នកដទៃសកម្មភាពរបស់យើងនឹងប្រាប់ទៅពិភពលោកដោយខ្លួនវាមិនចាំបាច់យើងស្រែកប្រកា សប្រាប់គេឯងឡើយ។ ទោះបីជាពាក្យសម្តីមិនអាចពន្យល់ដៃគូយើងឱ្យយល់ស្របតាមគំនិតរបស់យើងក៏ដោយក៏គំនិត«រស់ដោយពឹងពាក់គ្នាទៅវិញទៅមក»ប្រាកដជានឹងផ្សព្វផ្សាយទៅគ្រប់ទិសទីជាក់ជាមិនខានតាមរយៈភាពរីករាយក្នុងកិច្ចការងារស្ម័គ្រចិត្តដោយស្មោះមិនគិតប្រយោ ជន៍ផ្ទាល់ខ្លួនដែលយើងបង្ហាញ។ យោលទៅតាមឥរិយាបទបែបនេះរបស់យើងម្នាក់ៗ«វប្បធម៌នៃសេចក្តីមេត្តាករុណា» នឹងអាចផ្ទេរទៅជំនាន់ក្រោយបាន។

នៅពេលដែលខ្ញុំព្រះករុណាអាត្មាភាពសម្លឹងមើលពិភពលោកសព្វថ្ងៃនេះ ការពិតគឺថា វាមិនមែនជាកន្លែងដែលមនុស្សគ្រប់គ្នាអាចរស់នៅបានដោយងាយស្រួលនោះទេ។ នៅលេខបន្ទាប់ខ្ញុំព្រះករុណាអាត្មាភាពក៏ចង់លើកយកសកម្ម ភាពជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃមកនិយាយ ដើម្បីឱ្យយើងរាល់គ្នាអាចរស់នៅជាមួយគ្នាដោយសុខដុមរមនាបាន។

«កាសែតកូសេ» លេខខែ៨ឆ្នាំ២០២៦




# A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp